ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

NEC

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

Regulation + legislation

បទបញ្ជា និង នីតិវិធី

for

សំរាប់

audience and to solve the complaint

សវនាការ និង ដោះស្រាយបណ្តឹងជំទាស់

protesting complaint

បណ្តឹងតវ៉ា បណ្តឹងទាមទារ វិវាទកម្ម

និងការដាក់ពិន័យ

សំរាប់ការបោះឆ្នោតឆ្នាំ ១៩៩៨

06/03/98

ឧបសម្ព័ន្ធ ១០

បទបញ្ជា និងនីតិវិធីសំរាប់សវនាការនិងដោះស្រាយបណ្តឹងជំទាស់ បណ្តឹងតវ៉ា បណ្តឹងទាមទារ វិវាទកម្ម និង ការដាក់ពិន័យ :

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបង្កើតឱ្យមានបទបញ្ជា និងនីតិវិធីនេះសំរាប់ដំណើរការបើកសវនាការជាសាធារណៈ និងនីតិវិធីសំរាប់ដោះស្រាយបណ្តឹងទាស់ បណ្តឹងតវ៉ា បណ្តឹងទាមទារ និងបណ្តឹងសើរើ ឬបញ្ហាផ្សេងៗទៀតដែលទាក់ទងនឹងការដាក់ពិន័យផ្សេងៗ សំរាប់គ្រប់គ្រងនីតិវិធីរបស់ គ.ជ.ប និងនីតិវិធីរបស់គណៈកម្មការថ្នាក់ក្រោម ដូចជានៅថ្នាក់គណៈកម្មការខេត្ត-ក្រុង ឃុំ-សង្កាត់ រៀបចំការបោះឆ្នោតគណៈកម្មការការិយាល័យបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតដោយផ្អែកលើសំអាងដែលបានលើកឡើងខាងលើរួមមាន ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និង នីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សវនាការត្រូវធ្វើឡើងជាសាធារណៈ

១- សវនាការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការថ្នាក់ក្រោមទាំងឡាយត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែបញ្ហាណាដែលទាក់ទងនឹងការដាក់ពិន័យដែលជារឿងផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលការបើកសវនាការជាសាធារណៈអាចប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដែលត្រូវបានច្បាប់សន្មតជាមុនថាគ្មានកំហុស និងសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ពីស្ថាប័នមានសមត្ថកិច្ច ។

ការជូនដំណឹងអំពីសវនាការ

២- ការជូនដំណឹងជាលាយលក្ខអក្សរអំពីថ្ងៃបើកសវនាការ ត្រូវតែបានធ្វើឡើងនៅពេលណាដែលអាចធ្វើទៅបានទៅគ្រប់បុគ្គល ឬអង្គការទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវជំនុំជំរះនៅគណៈកម្មការឃុំ-សង្កាត់ ខេត្ត-ក្រុង ឬនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទាក់ទងនឹងការប្តឹងបណ្តឹងទាំងឡាយ លើការចុះឈ្មោះនៅមុនពេលបិទផ្សាយបញ្ជីបោះឆ្នោត ការជូនដំណឹងអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការបើកសវនាការទៅអ្នកប្តឹងទាស់ត្រូវធ្វើឱ្យបានមុនពេល

បិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដូចមានចែងក្នុងមាត្រា៥៧ ដល់ ៦២ នៃច្បាប់បោះឆ្នោត ។ ទំរង់បែបបទដែលមានលេខ ១០០១, ១០០២, ១០០៣ និង១០០៦ បានចែងបញ្ជាក់ និងពន្យល់អំពីរបៀបប្រើប្រាស់យ៉ាងច្បាស់នៅក្នុងចំនុច ៩.១. ៩.២ នៃឯកសារស្តីពីការចុះឈ្មោះបោះឆ្នោត បែបបទជូនដំណឹងលេខ ១០០៦ បានតំរូវឱ្យដាក់កាលបរិច្ឆេទ និងទីកន្លែងសំរាប់សវនាការដែលត្រូវជំនុំជំរះដោយគណៈកម្មការខេត្ត-ក្រុង និងពេលវេលាដែលបានកំនត់ដោយច្បាប់បោះឆ្នោតដែលបានអនុម័តបន្ថែមដោយរដ្ឋសភា ។ បើមានបណ្តឹងបន្តទៀតនោះគណៈកម្មការខេត្ត-ក្រុង ត្រូវផ្ញើរលិខិតជូនដំណឹងអំពីសវនាការទៅគណៈកម្មាធិការជាតិដោយប្រើទំរង់បែបបទលេខ១០០៦,១០០៧-ដោយចុះពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការទៅតាមការកំនត់របស់ច្បាប់នៃច្បាប់បោះឆ្នោត ។ គណៈកម្មាធិការជាតិត្រូវបំពេញទំរង់លេខ ១០០៦ និង ១០០៧ សំរាប់បណ្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

នាយកដ្ឋានសេវាកម្មច្បាប់នៃគណៈកម្មាធិការរៀបចំការបោះឆ្នោត ត្រូវរៀបចំប្រតិទិនកម្មវិធីសំរាប់បើកសវនាការសំរាប់ដោះស្រាយបណ្តឹងជំទាស់ ដែលកើតមានឡើងក្នុងពេលចុះឈ្មោះនៅថ្នាក់ជាតិ និងថ្នាក់ខេត្តដើម្បីធានាឱ្យការដោះស្រាយបណ្តឹងអាចប្រព្រឹត្តិទៅតាមពេលកំណត់ និងដើម្បីធានាឱ្យគណៈកម្មការថ្នាក់ក្រោម និងគណៈកម្មាធិការជាតិអាចធ្វើលិខិតជូនដំណឹងឱ្យទាន់ពេលទៅបុគ្គលដែលពាក់ព័ន្ធបណ្តឹង និងដើម្បីអាចធានាឱ្យមានការគោរពតាមពេលវេលាដែលមានចែងក្នុងច្បាប់បោះឆ្នោត។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការដែលពាក់ព័ន្ធត្រូវបើកសវនាការលើបណ្តឹងទាំងនេះជារៀងរាល់ថ្ងៃក្នុងអំឡុងម៉ោង ៩.០០ព្រឹកដល់ម៉ោង ១២.០០ថ្ងៃត្រង់លើកលែងតែថ្ងៃអាទិត្យ ។ ក្នុងករណីចាំបាច់សវនាការ អាចធ្វើនៅពេលម៉ោងផ្សេងពីការកំណត់នេះបាន ។

ទាក់ទងនឹងបណ្តឹងអំពីការចុះឈ្មោះបន្ទាប់ពីបិទផ្សាយបញ្ជីបោះឆ្នោត : យោងតាមមាត្រា៦៤-៦៦ នៃច្បាប់ស្តីពីការបោះឆ្នោត លិខិតជូនដំណឹងអំពីថ្ងៃសវនាការដែលទាក់ទងនឹងបណ្តឹងតវ៉ា បណ្តឹងទាមទារ បណ្តឹងជំទាស់លើការបាត់ឈ្មោះ ឬជំទាស់នឹងការចុះឈ្មោះបុគ្គលណាម្នាក់ និងត្រូវផ្ញើរទៅដល់បុគ្គល ឬអង្គការនោះដោយគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត ដែលជាប់ពាក់ព័ន្ធ ។ លិខិតជូនដំណឹងនេះ ត្រូវដាក់កាលបរិច្ឆេទទីកន្លែង និងកម្មវត្ថុនៃការជូនដំណឹងផង។

ប្រសិនបើមានការប្តឹងតវ៉ានឹងសេចក្តីសំរេចរបស់ខ្លួនគណៈកម្មការឃុំ-សង្កាត់ ឬខេត្តក្រុងត្រូវចេញលិខិតជូនដំណឹងអំពីថ្ងៃសវនាការ ដូចដែលមានចែងនៅក្នុងនីតិវិធីសំរាប់ដោះស្រាយបណ្តឹងលើការចុះឈ្មោះបោះឆ្នោតដែលកើតមានឡើង មុនពេលបញ្ជីបោះឆ្នោតត្រូវបានគេបិទផ្សាយ ។

ការប្រើប្រាស់ទំរង់បែបបទលេខ ១០០៤, ១០០៥, ១០០៦, ១០០៧ និង១០០៨ សំរាប់ធ្វើ

បណ្ដឹងជំទាស់ បណ្ដឹងតវ៉ា បណ្ដឹងទាមទារបានចែងនៅក្នុងចំនុចទី -៩.៣,និង-៩.៤ និងគំរូ និងឧទាហរណ៍ផ្សេងទៀតនៃឯកសារសំរាប់ចុះឈ្មោះបោះឆ្នោត ។ ទំរង់បែបបទនេះត្រូវប្រើប្រាស់សំរាប់បណ្ដឹងទាំងឡាយនៅគណៈកម្មការឃុំ-សង្កាត់ និងបណ្ដឹងផ្សេងៗទៀតដែលកើតមានមុនពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ទំរង់បែបបទនេះ ក៏ត្រូវប្រើប្រាស់ផងដែរសំរាប់បណ្ដឹងតវ៉ាពីគណៈកម្មការខេត្ត ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ គណៈកម្មការឃុំ-សង្កាត់ ដែលពាក់ព័ន្ធត្រូវបើកសវនាការក្នុងអំឡុងពេលពីម៉ោង ៩.០០ដល់ម៉ោង ៥.០០ ល្ងាច និងអាចបន្តទៀតបានប្រសិនបើចាំបាច់ ។ ហើយគណៈកម្មការខេត្ត-ក្រុង និងគណៈកម្មាធិការជាតិត្រូវបើកសវនាការក្នុងអំឡុងម៉ោង ៩.០០ដល់ម៉ោង ១២.០០ នឹងអាចបន្តទៅទៀតបានប្រសិនបើចាំបាច់ ។ សវនាការ ត្រូវបើកដោះស្រាយបណ្ដឹងជារៀងរាល់ថ្ងៃលើកលែងតែថ្ងៃអាទិត្យចាប់តាំងពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូងរហូតដល់ថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតស្ថាពរ ។

ប្រតិទិនសវនាការ

៣- នាយកដ្ឋានសេវាកម្មច្បាប់ ដោយមានការពិគ្រោះយោបល់ជាមួយនឹងអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់ប្រតិទិនមួយ សំរាប់ការបើកសវនាការនៅថ្នាក់គណៈកម្មាធិការជាតិ និងខេត្តទៅតាមពេលដែលបានកំនត់នៅក្នុងច្បាប់បោះឆ្នោតសំរាប់ដោះស្រាយបណ្ដឹងទាំងឡាយដែលកើតមានឡើង បន្ទាប់ពីការបិទបញ្ជីបោះឆ្នោតជាលើកចុងក្រោយ នាយកដ្ឋាននេះត្រូវធានាជំរុញអោយគណៈកម្មាធិការថ្នាក់ក្រោមទាំងអស់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចចេញ ឬផ្ដល់លិខិតជូនដំណឹងអំពីសវនាការនេះដល់បុគ្គល ឬអង្គការដែលទាក់ទងនឹងបណ្ដឹងនេះឱ្យបានទាន់ពេលវេលា ដូចដែលបានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ការរៀបចំសំណុំរឿង

៤- ការរៀបចំសំណុំរឿងទាំងឡាយ សំរាប់សវនាការជាភារកិច្ចរបស់គណៈកម្មការ ដែលពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានទទួលពាក្យបណ្ដឹងដោយមានជំនួយពីមន្ត្រីខាងសេវាកម្មច្បាប់ ឬក៏មន្ត្រី ដែលត្រូវបានគេតែងតាំងឱ្យសំរួលការងារនេះ ក្នុងករណីដែលគណៈកម្មការនោះគ្មានមន្ត្រីបំរើការងារខាងសេវាកម្មច្បាប់ ។ មន្ត្រីទាំងនោះ ត្រូវរៀបចំសំណុំរឿងអោយបានគ្រប់ជ្រុងជ្រោយរួមទាំងអង្គហេតុ និងឯកសារផ្សេងៗ ។ សេចក្ដីសំរេចទាំងឡាយរបស់គណៈកម្មការ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងត្រូវមានបញ្ជាក់ជាមូលហេតុច្បាស់លាស់ ។ ប្រសិនបើសេចក្ដី

សំរេចនេះត្រូវបានប្តឹងតវ៉ាទៅគណៈកម្មការ ដែលមានថានានុក្រមខ្ពស់ជាង ដើម្បីឱ្យសំរេចលើបណ្តឹងតវ៉ានោះ ដូចជាគណៈកម្មាធិការជាតិរៀបចំការឆ្នោត ឬក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណុំរឿងទាំងឡាយ រួមទាំងសេចក្តីសំរេច ដែលមានចែងជាមូលហេតុត្រូវតែបានបញ្ជូនទៅថ្នាក់លើផងដែរសំរាប់ធ្វើការពិចារណា និងសំរេច ។ បណ្តឹងតវ៉ាបន្តបន្ទាប់តំរូវអោយមានឯកសារគ្រប់គ្រាន់ រួមទាំងសេចក្តីសំរេចដែលមានចែងពីមូលហេតុទៅគណៈកម្មការ ដែលមានថានានុក្រមខ្ពស់ជាងនោះ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ សំណុំរឿងនេះក៏ត្រូវរៀបចំ និងអាចបន្ថែមឯកសារផ្សេងៗទៀតរហូតដល់ពេលជំនុំជំរះចុងក្រោយនៅថ្នាក់ក្រុមប្រឹក្សាធម្មនុញ្ញ លើកលែងតែមានការកំនត់ពិសេសដោយច្បាប់ដែលកំនត់ឱ្យបណ្តឹងត្រូវចប់ត្រឹមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬក៏ថ្នាក់ក្រោមនេះ ។

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

៥- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការថ្នាក់ក្រោមដែលត្រូវបានតែងតាំងឱ្យចូលរួមសវនាការដោះស្រាយបណ្តឹងនេះហៅថា ក្រុមប្រឹក្សាជំនុំជំរះ ហើយត្រូវមានសមាសភាពយ៉ាងតិចបីរូប ដូចតទៅ:

សំរាប់គណៈកម្មាធិការជាតិរួមមានប្រធាន អនុប្រធានគណៈកម្មាធិការជាតិ និងប្រធានអនុគណៈកម្មាធិការអចិន្ត្រៃយ៍សេវាកម្មច្បាប់ និងវិវាទកម្ម ។ ចំពោះគណៈកម្មការថ្នាក់ក្រោមនៅថ្នាក់ខេត្ត-ក្រុង ក្រុមប្រឹក្សាជំនុំជំរះរួមមាន ប្រធាន អនុប្រធានគណៈកម្មការខេត្ត-ក្រុង និងប្រធានអនុគណៈកម្មការផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។ ចំពោះខេត្តណាដែលមានសមាជិកគណៈកម្មការតែប្រាំនាក់ និងគណៈកម្មការឃុំ-សង្កាត់ ត្រូវមានសមាសភាពជំនុំជំរះបីនាក់ដែលរួមមាន ប្រធាន អនុប្រធាន និងលេខាធិការ ដែលត្រូវទទួលខុសត្រូវរួមគ្នាលើផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

តួនាទី និងភារកិច្ចរបស់នាយកដ្ឋាន និងផ្នែកសេវាកម្មច្បាប់

៦- ដោយមានការត្រួតពិនិត្យពីអគ្គលេខាធិការនាយកដ្ឋានសេវាកម្មច្បាប់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងផ្នែកសេវាកម្មច្បាប់ថ្នាក់ខេត្ត-ក្រុង ត្រូវសហការគ្នារៀបចំប្រតិទិនសវនាការ សំរាប់គណៈកម្មការគ្រប់ជាន់ថ្នាក់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ដោយផ្អែកលើបទបញ្ជានេះនាយកដ្ឋានសេវាកម្មច្បាប់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងផ្នែកសេវាកម្មច្បាប់នៃគណៈកម្មការខេត្ត-ក្រុង ត្រូវចុះធ្វើការស៊ើបអង្កេតលើអង្គហេតុនានា ដើម្បីរៀបចំសំណុំរឿង និងធ្វើជាទីប្រឹក្សាច្បាប់ទៅគ្រប់គណៈកម្មាធិការ ឬគណៈកម្មការដែលទទួលបន្ទុកជំនុំជំរះលើពាក្យបណ្តឹង ។

មន្ត្រីផ្នែកសេវាកម្មច្បាប់ថ្នាក់ខេត្តត្រូវទទួលបន្ទុកក្នុងការធ្វើអង្កេត និងរៀបចំសំណុំរឿង ឬផ្តល់ទីប្រឹក្សាផ្នែកច្បាប់ទៅថ្នាក់គណៈកម្មការឃុំ_សង្កាត់ផងដែរ ។

នីតិវិធីបើកសវនាការ

៧_ ការបើកសវនាការតាមនីតិវិធីនៃប្រព័ន្ធច្បាប់ស៊ីវិល ក្រុមប្រឹក្សាជំនុំជំរះអាចធ្វើសវនាការតាមនីតិវិធីសង្ខេប ឬសវនាការប្រតិបក្សតែម្តង ឬក៏អាចប្រើសវនាការសួរដេញដោលរកហេតុផល ។ សវនាការនេះត្រូវគោរពទៅតាមពេលវេលា និងទំរង់បែបបទដែលបានកំនត់ដោយច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលតំរូវឱ្យការស៊ើបអង្កេតត្រូវធ្វើក្នុងរយៈពេលខ្លី ។

៧.១_ ចំពោះការដោះស្រាយបណ្តឹងជំទាស់ បណ្តឹងទាមទារ ឬ បណ្តឹងតវ៉ាដែលទាក់ទងនឹង ៖

៧.១.១_ ការចុះឈ្មោះបោះឆ្នោត ។

៧.១.២_ ការអនុវត្តន៍តួនាទីរបស់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ដែលមានចែងក្នុងមាត្រា ១០១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៧.១.៣_ ការប្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោតទៅគណៈកម្មការខេត្ត ដែលមានចែងក្នុងមាត្រា ១១១ ។

៧.១.៤_ ការប្តឹងជំទាស់របស់គណបក្សនយោបាយនឹងលទ្ធផលបោះឆ្នោតទៅគណៈកម្មាធិការជាតិស្របតាមមាត្រា ១១៤ ដល់ ១១៧ ។

៧.១.៥_ បទបញ្ញត្តិនៃបទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោតដែលទាក់ទងនឹង ៖

_ការអុកឡុក ឬរុះរើសំភារៈបរិក្ខាចុះឈ្មោះបោះឆ្នោត

_ប័ណ្ណបោះឆ្នោត ឬប្រើហឹង្សាក្នុងពេលយុទ្ធនាការបោះឆ្នោត

_តវ៉ាជំទាស់ និងការរំលោភនឹងបទញ្ជនៃយុទ្ធនាការឃោសនា

_បណ្តឹងតវ៉ាអំពីប្រតិបត្តិការរៀបចំការបោះឆ្នោត

_សេចក្តីសំរេចនៅការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

_សន្លឹកឆ្នោតអសុពលភាព និង

_បណ្តឹងជំទាស់ដោយភ្នាក់ងារគណបក្សនយោបាយលើការរាប់សន្លឹកឆ្នោត

៧.១.៦_ ករណីរឿងក្តីផ្សេងៗទៀតដែលសំរេចដោយក្រុមប្រឹក្សាជំនុំជំរះទាក់ទងនឹងបញ្ហាដែលលើកឡើងខាងលើក្រុមប្រឹក្សាជំនុំជំរះត្រូវប្រើនីតិវិធីសង្ខេប ឬនីតិវិធីប្រតិបក្ស ។

៧.២_ ទាក់ទងនឹងសេចក្តីសំរេចលើពាក្យបណ្តឹងនានាដែលច្បាប់បោះឆ្នោតបានលើកឡើងដូចជា ៖

៧.២.១_ សិទ្ធិ និងភារកិច្ចរបស់គណៈកម្មាធិការជាតិដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់បោះឆ្នោត ។

៧.២.២. ទោសបញ្ញត្តិ ដែលមានចែងក្នុងមាត្រា ១២២ ដល់ ១៣៣

.២.៣ បទបញ្ញត្តិនានានៃបទបញ្ជា និងនីតិវិធីដែលទាក់ទងនឹង

ការតែងតាំងសមាជិកភាពរបស់គណៈកម្មការ

_ការមិនរក្សាពាក្យសម្បថ

_ការបាត់បង់សំភារៈបរិក្ខា

_ការចាត់វិធានការណ៍ដាក់វិន័យ ឬពិន័យ

_កិច្ចអង្កេតការណ៍នៃកងយោធពលខេមរៈភូមិន្ទ និងនគរបាល និង

_បញ្ហាផ្សេងៗទៀត

៧.២.៤_ រឿងក្ដីផ្សេងៗទៀត ដែលសំរេចដោយក្រុមប្រឹក្សាជំនុំជំរះក្រុមប្រឹក្សាជុំនុំជំរះត្រូវនីតិវិធីសវនាការលំអិតជជែកដេញដោលចំពោះបណ្ដឹង ដែលទាក់ទងនឹងករណីដែលបានលើកឡើងខាងលើនេះ ។

៧.៣_ ដើម្បីសំរេចគោលបំណងនេះ និយមន័យនៃប្រភេទសវនាការនីមួយៗមានដូចខាងក្រោម ៖

1- **Summary** : (សវនាការសង្ខេប) មានន័យថាជាសវនាការដែលគ្មានទំរង់បែបបទ ។ ក្រុមប្រឹក្សាជុំនុំជំរះធ្វើសេចក្ដីសំរេចមួយឆ្លើយតបនៅពេលយល់ឃើញថាវាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ ។

2- **Adversarial** : (សវនាការប្រតិបក្ស) មានន័យថាជាសវនាការដែលបើកឱ្យភាគីជំទាស់ជជែកតទល់គ្នាអំពីរឿងវិវាទ ។ លទ្ធផលនៃសវនាការនេះ និងផ្ដល់អំណោយផលចំពោះភាគីតែមួយប៉ុណ្ណោះក្នុងចំណោមភាគីទាំងពីរនេះ ។

3-**Inquisitional**: (សវនាការដេញដោល) មានន័យថាជាសវនាការជជែកសួររកហេតុផលដោយចៅក្រម ឬក្រុមប្រឹក្សាជុំនុំជំរះដែលពួកគេដើរតួរនាទីសំខាន់នៅក្នុងរឿងក្ដី ។ ក្នុងសវនាការប្រភេទនេះទាំងតុលាការ ទាំងគូក្ដីជាអ្នកទទួលខុសត្រូវក្នុងការប្រមែលប្រមូលអង្គហេតុផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងរឿងក្ដី ប៉ុន្តែក្រុមប្រឹក្សាជុំនុំជំរះមានតួនាទីទទួលខុសត្រូវសំខាន់បំផុតក្នុងការជាអ្នកតាំងជាសំនួរដល់សាក្សី ចំណែកគូក្ដីនៃបណ្ដឹងមានតួនាទីបន្ទាប់បន្សំប៉ុណ្ណោះ ។

៧.៤_ នីតិវិធីប្រើប្រាស់ក្នុងសវនាការសង្ខេប និងសវនាការប្រតិបក្សមានដូចខាងក្រោមនេះ ៖

៧.៤.១_ នៅពេលសំនុំរឿងបានទៅដល់គណៈកម្មការដំបូងដែលទទួលបន្ទុកដោះស្រាយបណ្ដឹង ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ភាគី " ក " ដែលអាចជាបុគ្គល ឬ

អង្គការប្តឹងសុំជំនួយពីក្រុមប្រឹក្សាជំនុំជំរះគឺជាដើមបណ្តឹង ហើយភាគី "ខ" ដែលជាបុគ្គល ឬ អង្គការ ដែលត្រូវបានគេប្តឹងនោះជាចុងចំលើយ ។

៧.៤.២ ក្នុងពេលដែលមានការប្តឹងតវ៉ាសេចក្តីសំរេចថ្នាក់ក្រោម ភាគី ឬ អង្គការ ដែលប្តឹងតវ៉ានោះឱ្យឈ្មោះថា អ្នកប្តឹងតវ៉ា ហើយភាគី ខ គណៈកម្មការថ្នាក់ក្រោមត្រូវបានគេប្តឹងតវ៉ានោះជាចុងចំលើយ

៧.៤.៣_ ដើមបណ្តឹងជំទាស់ ឬដើមបណ្តឹងតវ៉ាអាចរកមេធាវីផ្ទាល់ខ្លួនដើម្បីតំណាងឱ្យខ្លួនបាន មេធាវីរបស់ចុងចំលើយ ត្រូវតែជាសមាជិកនៃផ្នែកសេវាកម្មច្បាប់នៃគណៈកម្មការថ្នាក់ទីមួយដែលទទួលបណ្តឹងនេះ ។ ក្នុងករណីដែលមានការប្តឹងតវ៉ាទៅក្រុមប្រឹក្សាជំនុំជំរះថ្នាក់លើ មេធាវីរបស់ចុងចំលើយ ត្រូវតែជាមេធាវីដែលបានការពារនៅថ្នាក់ក្រោមដែលគេប្តឹងតវ៉ាមកថ្នាក់លើនេះ ។ ទោះជាយ៉ាងណាក៏ដោយនៅគ្រប់ពេលដោះស្រាយបណ្តឹងទាំងអស់ ក្រុមប្រឹក្សាជំនុំជំរះ អាចត្រូវបានចូលរួមដោយមន្ត្រីនៃនាយកដ្ឋានសេវាកម្មច្បាប់នៅគណៈកម្មាធិការជាតិនិងផ្នែកសេវាកម្មច្បាប់នានានៅថ្នាក់គណៈកម្មការនានានៅគ្រប់ពេលបើកសវនាការជំនុំជំរះលើពាក្យបណ្តឹង ។ ដូចនេះទាំងក្រុមប្រឹក្សាជំនុំជំរះ ទាំងភាគីមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់រៀងៗខ្លួន ។

៧.៤.៤_ ការបង្ហាញអង្គច្បាប់ និងអង្គហេតុទៅក្រុមប្រឹក្សាជំនុំជំរះ ៖

៧.៤.៤.១_ អ្នកដាក់ពាក្យប្តឹងជំទាស់ ឬប្តឹងតវ៉ា អាចរាយការណ៍ជាលាយលក្ខ័អក្សររបស់ខ្លួនអំពីបញ្ហាដែលកើតឡើង ។ ហើយចុងចំលើយនៃបណ្តឹងនេះក៏អាចធ្វើកំណត់ ហេតុបណ្តឹងអំពីបញ្ហានានាដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាង ។

៧.៤.៤.២_ អ្នកដាក់ពាក្យប្តឹងជំទាស់ ឬប្តឹងតវ៉ា ត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនហើយអាចបង្ហាញឯកសារជាភស្តុតាងនានា ឬសាក្សីបំភ្លឺនានា ដែលបានស្បថជាមុនថានិយាយតែកាពិត ហើយដែលមានប្រយោជន៍ដល់រឿងក្តីរបស់ខ្លួន ចុងចំលើយអាចតាំងជាសំនួរ ទៅដើមបណ្តឹង និងសាក្សីរបស់គេអំពីភស្តុតាងដែលគេមាន ។ សមាជិកនៃក្រុមប្រឹក្សាជំនុំជំរះ អាចតាំងជាសំនួរទៅអ្នកប្តឹងជំទាស់ ឬ តវ៉ា ឬ សាក្សីរបស់ពួកគេបាន ។

៧.៤.៤.៣_ ចុងចំលើយ ត្រូវដាក់ពាក្យប្តឹងរបស់ខ្លួន ដើម្បីសំរេចបណ្តឹងនេះ ចុងចំលើយអាចបំពេញនូវសំនុំរឿងរបស់ខ្លួន ចុងចំលើយអាចដាក់បញ្ជូនូវឯកសារដែលជាភស្តុតាងនានា ឬសាក្សីបំភ្លឺនានា ដែលបានស្បថថានិយាយតែការពិត ហើយមានប្រយោជន៍សំរាប់ខ្លួន ដើមបណ្តឹងជំទាស់

ឬដើមបណ្តឹងតវ៉ា អាចតាំងជាសំនួរទៅកាន់ចុងចំលើយឬសាក្សីរបស់គេ អំពីវត្ថុតាងនានាដែលគេមាន ។ សមាជិកនៃក្រុមប្រឹក្សាជំនុំជំរះ អាចសួរចំលើយទៅចុងចំលើយ ឬទៅសាក្សីរបស់គេ

ចុងចំលើយ អាចដាក់ទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវី ដើម្បីឆ្លើយតបនិងទឡ្ហីករណ៍របស់ដើមបណ្តឹងជំទាស់ ឬ តវ៉ា ។

៧.៤.៤.៥_ ក្រុមប្រឹក្សាជំនុំជំរះ ត្រូវធ្វើការសំរេចសេចក្តីជាសំងាត់ (ដោយដាច់ដោយឡែក) ហើយត្រូវចេញសាលក្រមជាលាយលក្ខ័អក្សរដោយមានចែងជាមូលហេតុ និងទៅតាមពេលវេលាដែលបានកំណត់ដោយច្បាប់បោះឆ្នោត ។

៧.៤.៤.៦_ សាលជំរះក្តី ត្រូវរៀបចំសរសេររបាយការណ៍ដែលកើតមានក្នុងសវនាការ និងដោយ មានជំនួយពីនាយកដ្ឋានសេវាកម្មច្បាប់ និងផ្នែកសេវាកម្មច្បាប់នានាក្នុងការសរសេរកំណត់ហេតុសវនាការ ឱ្យបានត្រឹមត្រូវតាមអ្វីដែលកើតមានឡើង និងថតសំលេងទុកជាឯកសារ ។ ឯកសារ និងកាសែតសំលេងនៃសវនាការនេះជាផ្នែកមួយនៃសំណុំរឿង ។ សំណុំរឿងនេះ ត្រូវផ្ញើរទៅគ្រប់សាលាជំរះក្តីមានថានានុក្រមខ្ពស់ជាង ។

៧.៤.៤.៧_ មធ្យោបាយបង្ហាញភស្តុតាងដែលប្រើប្រាស់ក្នុងសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកអនុវត្តក្នុងដំណើរការសវនាការនេះ ។

៧.៤.៤.៨_ សក្ខីកម្មទាំងឡាយរបស់ដើមបណ្តឹងជំទាស់ បណ្តឹងតវ៉ា ចុងចំលើយ ត្រូវធ្វើឡើងដោយមានសច្ចាប្រណិធានជាមុន ។ ការធ្វើសម្បថបំពាននឹងត្រូវបានចោទប្រកាន់ឱ្យមានទោស ។

៧.៤.៥_ ក្រុមប្រឹក្សាជំនុំជំរះ ត្រូវតែងតាំងមេធាវីឯកជនឱ្យជួយការពារបុគ្គលដែលទីទាល់ក្រគ្មានលទ្ធភាពអាចជួលមេធាវីបាន ។

៧.៥_ នីតិវិធីនៃសវនាការសួរដេញដោលនៅចំពោះមុខក្រុមប្រឹក្សាជំនុំជំរះមានដូចខាងក្រោម ៖

៧.៥.១_ សវនាការជំនុំជំរះ ត្រូវប្រើនីតិវិធីរដ្ឋប្បវេណីដែលបានលើកឡើងនៅក្នុងនីតិវិធីសង្ខេបនិងបដិបក្សខាងលើ ។ ក្រុមប្រឹក្សាជំនុំជំរះ អាចប្រើប្រាស់បីដំណាក់កាលដើម្បីដោះស្រាយបណ្តឹងនេះ គឺដំណាក់កាលសម្រុះសម្រួល ដំណាក់កាលស៊ើបអង្កេត និងបើកសវនាការ

ជំរះក្ដី ។ ការសម្រុះសម្រួលនេះអាចប្រើប្រាស់ក្នុងកាលៈទេសៈ ឬបញ្ហាវិវាទណាដែលអាចធ្វើទៅបានអាស្រ័យលើមូលវិចាររបស់ក្រុមប្រឹក្សាជំនុំជំរះក្ដី ។

៧.៥.២ ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ឬវាមិនមែនជាវិធីសាស្ត្រសមស្របសំរាប់ដោះស្រាយវិវាទនេះទេ សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាជំនុំជំរះ ដែលត្រូវតែងតាំងសមាជិកម្នាក់របស់ខ្លួនជាសុភាចាបុរសដើម្បីប្រតិបត្តិការអង្កេតលើបញ្ហា ដែលចោទឡើងក្នុងបណ្ដឹងជំទាស់ ឬ បណ្ដឹងតវ៉ា និងប្រមូលភស្តុតាងនានា និងសំអាងច្បាប់នានាសំរាប់បណ្ដឹង និងដើម្បីអាចផ្ដល់ពត៌មានជាក់លាក់ និងច្បាស់លាស់សំរាប់សវនាការទៅក្រុមប្រឹក្សាជំនុំជំរះ ។ ដំណាក់កាលទាំងនេះត្រូវតែបានយកមកប្រើប្រាស់ក្នុងសវនាការ គឺភាគីត្រូវបង្ហាញខ្លួនចំពោះសវនាការ ហើយសុភាចារបុរសធ្វើប្រតិបត្តិការអង្កេតអំពីបញ្ហាដែលចោទឡើង ។ ភាគីនៃរឿងក្ដីទាំងឡាយដូចបានលើកឡើងក្នុងកថាខណ្ឌទី ៦ វាក្យខណ្ឌ ១.២ អាចតំណាងដោយមេធាវី ឬអ្នកតំណាងតាមបែបបទដូចមានចែងក្នុងកថាខណ្ឌទី ៦ វាក្យខណ្ឌទី ៣ ។

៧.៥.៣_ តាមបង្គាប់របស់សាលាជំនុំជំរះភាគីទាំងឡាយ ត្រូវដាក់ជូនសំអាងសង្ខេបដែលមានប្រយោជន៍ដល់បណ្ដឹង និងឆ្លើយបញ្ជាក់ទៅនឹងការសន្និដ្ឋានរបស់ចៅក្រមស៊ើបអង្កេតដែលនឹងត្រូវសួរដេញដោលទៅភាគី ឬសាក្សីដោយផ្ទាល់ដើម្បីបានចំលើយផ្ទាល់ពីពួកគេ។ ការសួរចំលើយនេះនឹងធ្វើតាមបែបបទដែលកំណត់ដោយស្ថាប័នក្រុមប្រឹក្សាជំនុំជំរះ ។

៧.៥.៤_ សុភាចារបុរសនៃស្ថាប័នជំនុំជំរះក្ដី អាចធ្វើមូលវិចារណ៍លើចំលើយរបស់ភាគីនីមួយៗ ហើយអាចស្នើរសុំឱ្យគេបង្ហាញភស្តុតាងដូចជា ឯកសារផ្សេងៗ សាក្សីបំភ្លឺ កោសល្យវិច័យ និងអាចចុះធ្វើប្រតិបត្តិការអង្កេតនៅកន្លែងប្រភពភស្តុតាងផ្សេងៗ ដែលភាគីបានលើកឡើង។

៧.៥.៥_ សុភាចារបុរសនៃស្ថាប័នជំរះសេចក្ដី ត្រូវរៀបចំចងក្រងសំណុំរឿង ឯកសារផ្សេងៗ ដែលភាគីបានដាក់បំភ្លឺឱ្យបានពេញលេញសំរាប់សវនាការជំរះក្ដី ហើយបញ្ជូនគ្រប់ឯកសារទាំងឡាយដែលមានរួមទាំងសំនុំរឿងផ្សេងៗដូចមានចែងក្នុងវាក្យខ័ណ្ឌទី៤ ខាងលើ ។ ស្ថាប័នជំនុំជំរះ ត្រូវបើកសវនាការសំរេចលើបណ្ដឹងនោះតែម្ដង ។

៧.៥.៦_ ការឆ្លើយបំភ្លឺនានាទៅស្ថាប័នជំរះក្ដី ត្រូវធ្វើសច្ចាប្រណិធាន និងសន្យាទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើខ្លួនបំពានពាក្យសម្បថ ។

៧.៥.៧_ មធ្យោបាយនៃការបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងប្រទេសកម្ពុជាត្រូវបានយកមកប្រើក្នុងនីតិវិធីនេះ ។

ការកោះហៅសាក្សីនិងវិធានការណ៍សំរាប់អ្នកមិនស្តាប់បង្គាប់

ក្រុមប្រឹក្សាជំនុំជំរះ ត្រូវតែងតាំងមេធាវីឯកជនដើម្បីជួយកូនក្តីដែលទីទាល់ក្រគ្មានលទ្ធភាពរក មេធាវី ។ ស្ថាប័នជំនុំជំរះក្តីមានអំណាចចេញដីកាកោះហៅសាក្សីឱ្យចូលរួម និងមានសិទ្ធិអំណាចសំរេច និងចាត់វិធានការណ៍នេះចំពោះជនណាមួយដែលមិនស្តាប់បង្គាប់ស្ថាប័នជំនុំជំរះដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសាលាជំរះក្តីដែលនៅជាធរមាន ។

គណនីយដំកល់ប្រាក់ពិន័យ

៩_ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបង្កើតគណនីយតំកល់ដោយមិនអាចដកហូតបាន រហូតដល់រដ្ឋសភា ឬស្ថាប័នមានសមត្ថកិច្ចណាមួយកំណត់អំពីការប្រើប្រាស់នៃប្រាក់នេះ ។

ការផ្តួចផ្តើមស៊ើបអង្កេតដោយ គ.ជ.ប

១០_ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាចឆន្ទានុសិទ្ធិធ្វើប្រតិបត្តិការអង្កេត ដោយគ្មានការកំនត់លើគ្រប់បញ្ហា ដែលមានចែងក្នុងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ឬក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំចាំបាច់មានបណ្តឹងពីបុគ្គល ឬអង្គការណាមួយឡើយ ដើម្បីធានាឱ្យមានការគោរពច្បាប់ និងដើម្បីការពារប្រក្រតីភាពនៃការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងត្រឹមត្រូវ ។ ដើម្បីសំរេចគោលបំណងខាងលើនេះ អគ្គលេខាធិការដោយពិគ្រោះយោបល់ជាមួយប្រធាននាយកដ្ឋានសេវាកម្មច្បាប់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែងតាំងអ្នកស៊ើបអង្កេតដើម្បីផ្តល់ពត៌មាននៃការអង្កេតរបស់ខ្លួនដល់អគ្គលេខាធិការ និងប្រធានអនុគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកសេវាកម្មច្បាប់ ដែលត្រូវចូលរួមក្នុងក្រុមប្រឹក្សាជំនុំជំរះនៅថ្នាក់គណៈកម្មាធិការជាតិក្នុងការសំរេចសេចក្តីលើបញ្ហានានានៅក្នុងសវនាការជាសធារណៈ និងដើម្បីអនុវត្តអំណាចតុលាការចំពោះសាក្សីណាដែលមិនព្រមចូលខ្លួនតាមដីកាកោះ ។ អ្នកស៊ើបអង្កេតទាំងឡាយមិនត្រូវបានអនុញ្ញាតិឱ្យចូលរួមក្នុងសវនាការនេះឡើយលើកលែងតែពេលដែលត្រូវនាំខ្លួនសាក្សី និងពេលដែលខ្លួនត្រូវផ្តល់ចំលើយលើការស៊ើបអង្កេតរបស់ខ្លួនតែប៉ុណ្ណោះ ។

នីតិវិធី និងសវនាការនៅការិយាល័យចុះឈ្មោះ និងនៅការិយាល័យបោះឆ្នោត

១១ នៅពេលដែលមានបញ្ហាកើតឡើងនៅពេលចុះឈ្មោះពេលបោះឆ្នោត ឬពេលរាប់សន្លឹកឆ្នោតប្រធានគណៈកម្មការការិយាល័យបោះឆ្នោតនោះអាចសំរេចសេចក្តីទៅតាមកាលៈទេសៈជាក់ស្តែង ដែលសេចក្តីសំរេចនោះជាសេចក្តីសំរេចស្ថាពរ ប៉ុន្តែប្រធានត្រូវរង់ចាំឆ្លើយតបទៅនឹងបណ្តឹងជំទាស់ បណ្តឹងតវ៉ា និងបណ្តឹងផ្សេងៗទៀតដែលទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ពីបុគ្គល ឬពីអង្គការនានា ។ ប្រធានត្រូវរក្សាសំណុំរឿងទាំងនេះទុកសំរាប់ជាការពិចារណារបស់គណៈកម្មការដែលមានថានានុក្រមខ្ពស់ជាង ដែលអាចត្រូវការសំរាប់ជាមូលវិចារក្នុងពេលសវនាការលើបណ្តឹងតវ៉ា ។ ប្រធាន ត្រូវសួរយោបល់សមាជិកផ្សេងទៀតមុនពេលធ្វើសេចក្តីសំរេចជាចុងក្រោយ ។ ដូច្នេះហើយបានជា គណៈកម្មាធិការជាតិបង្កើតឱ្យមានបទបញ្ជា និងនីតិវិធីនេះឡើងសំរាប់ដោះស្រាយបណ្តឹងទាស់ បណ្តឹងតវ៉ា បណ្តឹងទាមទារ និងការដាក់ពិន័យនេះ ។ បទបញ្ជានេះនឹងចូលជាធរមានភ្លាមបន្ទាប់ពីថ្ងៃចុះហត្ថលេខា ។

បទបញ្ជា និង នីតិវិធីនេះ ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអនុម័តនៅថ្ងៃទី 04 ខែ ០៤ ឆ្នាំ ១៩៩៨ ។

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ព្រឹទ្ធាចារ្យ ឆេង ~ ផុន

សំគាល់ : សភាជាតិបានធ្វើវិសោធនកម្មលើច្បាប់បោះឆ្នោត ដែលពាក់ពន្ធ័នឹងរយៈពេលនៃការធ្វើបណ្តឹងជំទាស់លើការបដិសេធមិនឱ្យចុះឈ្មោះគណបក្សនយោបាយ ឬបេក្ខជន ឬចុះឈ្មោះបោះឆ្នោតរួមទាំងការធ្វើបណ្តឹងជំទាស់ទៅនឹងការបាត់ឈ្មោះ ឬជំទាស់នឹងឈ្មោះណាមួយដែលមាននៅលើបញ្ជីបោះឆ្នោតដំបូង គំនូសបំព្រួញខាងក្រោមនេះសំរាប់បង្កលក្ខណៈងាយស្រួលដល់ការអនុវត្តនីតិវិធីខាងលើឱ្យបានត្រឹមត្រូវ និងច្បាស់លាស់

១_ នីតិវិធីសំរាប់ដោះស្រាយវិវាទទាក់ទងនឹងការចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជន



២_ ការដោះស្រាយបណ្ដឹងតវ៉ាដែលកើតមានឡើងក្នុងពេលចុះឈ្មោះបោះឆ្នោតនៅមុនពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង



៣_ **នីតិវិធីសំរាប់ដោះស្រាយបណ្តឹងជំទាស់នឹងការចុះឈ្មោះ បន្ទាប់ពីការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង (សំរាប់ការបោះឆ្នោត ឆ្នាំ១៩៩៨)**

នៅពេលដែលការចុះឈ្មោះចប់រួចរាល់ហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបិទផ្សាយ បញ្ជីបោះឆ្នោតដំបូង [illegible] បណ្តឹងជំទាស់ [illegible] បណ្តឹងទាមទារ និងបណ្តឹងតវ៉ា អាចធ្វើបាននៅពេល បន្ទាប់មក [illegible] នេះបង្ហាញពីវិធី និងពេលវេលាដែលសកម្មភាពទាំងនេះត្រូវអនុវត្ត

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

↓

ប្តឹងតវ៉ាទៅ គ.ឃ / ស.ប	ប្តឹងតវ៉ាក្នុង ៣ ថ្ងៃ
គ.ឃ / ស.ប សំរេចការបដិសេធការចុះឈ្មោះ	សំរេចក្នុង ១ ថ្ងៃ
ប្តឹងតវ៉ាទៅ គ.ខ / ក.ប	ប្តឹងតវ៉ាក្នុង ៣ ថ្ងៃ
ក.ខ ក.បសំរេចបដិសេធការសុំចុះឈ្មោះ	សំរេចក្នុង ៥ ថ្ងៃ
ប្តឹងតវ៉ាទៅ គ.ជ.ប	ប្តឹងតវ៉ាក្នុង ៣ ថ្ងៃ
គ.ជ.ប បដិសេធការចុះឈ្មោះ	សំរេចក្នុង ៥ ថ្ងៃ
បន្តប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ	ប្តឹងតវ៉ាក្នុង ២ ថ្ងៃ
សំរេចសេចក្តីបិទផ្លូវតវ៉ា	សំរេចក្នុង ៥ ថ្ងៃ

៤_ នីតិវិធីសំរាប់ដោះស្រាយលើបណ្តឹងតវ៉ា អំពីលទ្ធផលនៃការបោះឆ្នោត
(សំរាប់ការបោះឆ្នោតឆ្នាំ ១៩៩៨)